ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងបរិស្ថាន

Ministry of Environment

លេខ: ១៤៥ ប្រក.......ប.ស្ក

រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ២០១០

# ប្រកាស

## ស្តីពីការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ "បឹងធន្លេម្រេច" ភូមិអូរពោធិ ឃុំមេណឺយ ស្រុករវៀង ខេត្តព្រះវិហារ ក្នុងដែនជម្រកសត្វព្រៃបឹងពែរ

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងបរិស្ថាន

- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី តំបន់ការពារធម្មជាតិ

-បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន

- បានឃើញអនុក្រឹត្យលេខ ៣៧ អនក្រ.បក ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០០៨ ស្តីពីការតម្លើងនាយកដ្ឋានការពារ-អភិរក្សធម្មជាតិ របស់ក្រសួងបរិស្ថាន ទៅជាអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ

-តាមតម្រូវការចាំបាច់របស់សហគមន៍មូលដ្ឋាន។

## សំរេច

**ប្រការ ១ :** រៀបចំបង្កើតសហគមន៍តំបន់ការពារធម្មជាតិ **"បឹងធន្លេម្រេច"** ដែលស្ថិតនៅក្នុងភូមិអូរពោធិ ឃុំមេណឺយ ស្រុករវៀង ខេត្តព្រះវិហារ នៃដែនជម្រកសត្វព្រៃបឹងពែរ។

**ប្រការ ២ :** សហគមន៍តំបន់ការពារធម្មជាតិ **"បឹងទន្លេស្រមេច"** ក្នុងដែនជម្រកសត្វព្រៃបឹងពែរ មានផ្ទៃដីទំហំ **១៧២២ហិចតា** បានកំណត់ទីតាំងព្រំប្រទល់ក្នុងផែនទី ដែលមានអាប់ស៊ីស និងកូអ័រដោនេ ដូចខាងក្រោម :

| ចំណុច | អាប់ស៊ីស X | កូអ័រដោនេ Y | ចំណុច | អាប់ស៊ីស X | កូអ័រដោនេ Y |
|---|---|---|---|---|---|
| A | 498503 | 1450501 | J | 502582 | 1452941 |
| B | 497659 | 1451335 | K | 503589 | 1453856 |
| C | 497916 | 1451613 | L | 504726 | 1454987 |
| D | 498374 | 1452262 | M | 504250 | 1455490 |
| E | 503630 | 1456269 | N | 501412 | 1453142 |
| F | 503630 | 1457272 | O | 500617 | 1452713 |
| G | 506213 | 1457222 | P | 499636 | 1451721 |
| H | 506163 | 1455040 | Q | 499797 | 1451475 |
| I | 503329 | 1452256 | | | |

**ប្រការ ៣ :** ការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ **"បឹងទន្លេស្រមេច"** នៃដែនជម្រកសត្វព្រៃបឹងពែរ និងការប្រើប្រាស់ធនធានធម្មជាតិក្នុងតំបន់នេះ ត្រូវចុះកិច្ចព្រមព្រៀងជាមួយរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ នៃក្រសួងបរិស្ថាន ហើយសហគមន៍ត្រូវមានលក្ខន្តិកៈ និងផែនការគ្រប់គ្រង ស្របតាមច្បាប់ស្តីពីតំបន់ការពារធម្មជាតិ។

**ប្រការ ៤ :** អគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានបច្ចេកទេស នាយកដ្ឋានពាក់ព័ន្ធ កម្រងតំបន់ការពារធម្មជាតិស្ទឹងសែន មន្ទីរបរិស្ថានខេត្តព្រះវិហារ ដែនជម្រកសត្វព្រៃបឹងពែរ និងសហគមន៍តំបន់ការពារធម្មជាតិ **"បឹងទន្លេស្រមេច"** នៃដែនជម្រកសត្វព្រៃបឹងពែរ ត្រូវសហការអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាទៅ

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

ម៉ុក_ម៉ារ៉េត

បណ្ឌិត.ជីវវិទ្យា

<u>ចម្លងជូនៈ</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- សាលាខេត្តព្រះវិហារ
- ឯកសារ-កាលប្បវត្តិ